**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខ** ២៧ សសរ

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារ ដឹកនាំផែនហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៥០៥ អនក្រ.តត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអនុគណកម្មការទទួលភារកិច្ចរៀបចំព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ ៖**

ត្រូវបានបង្កើតក្រុមការងារមួយដើម្បីទទួលខុសត្រូវផែនដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២- លោកជំទាវ | **ម៉ិញ្ញ ភុសនី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម | **គង់ ភន្លារ៉ា** | អនុរដ្ឋលេខាធិការ | ទទួលបន្ទុកដឹកនាំផែនទី២ |
| ៤- ឯកឧត្តម | **ហ៊ី វីរៈ** | អនុរដ្ឋលេខាធិការ | ទទួលបន្ទុកដឹកនាំផែនទី៣ |
| ៥- លោកជំទាវ | **ឆឹង ស៊ីមន** | អនុរដ្ឋលេខាធិការ | ទទួលបន្ទុកដឹកនាំផែនទី៤ |

**ក្រុមការងារនេះមានភារកិច្ចៈ**

ទទួលខុសត្រូវលើការដឹកនាំផែន ដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ

**ប្រការ២ ៖**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ,ថ្ងៃទី ៣០ ខែ ០៤ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ភឿង-សកុណា

**ចម្លងជូនៈ**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការបុណ្យជាតិ- អន្តរជាតិ
- ដូចប្រការ១
- ឯកសារ